# ការពារកុមារ
# ពីការរំលោភបំពានផ្លូវភេទ

## -កិច្ចការពារកុមារក្នុងវិស័យទេសចរណ៍នៅកម្ពុជា-

**ឯកឧត្តម ហោ សារុន**
អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍
ប្រធានគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

# ព្រះរាជាណាចក្រកម្ពុជា




**ទីតាំង៖** តំបន់អាស៊ីអាគ្នេយ៍

មានព្រំដែនជាប់ប្រទេសថៃ ឡាវ វៀតណាម និងឈូងសមុទ្រថៃ

**ផ្ទៃក្រឡា៖** ១៨១.០៣៥ គីឡូម៉ែត្រការ៉េ

**ប្រជាជន៖** ១៦ លាននាក់

**រាជធានី៖** ភ្នំពេញ

**អាកាសធាតុ៖** ម៉ូសុងតំបន់ត្រូពិក

- រដូវប្រាំង (វិច្ឆិកា ដល់មេសា)
- រដូវវស្សា (ឧសភា ដល់តុលា)

# វិស័យទេសចរណ៍នៅកម្ពុជា

មូលដ្ឋានគ្រឹះនៃគោលនយោបាយអភិវឌ្ឍន៍វិស័យទេសចរណ៍នៅកម្ពុជាគឺ៖

**ទេសចរណ៍វប្បធម៌ និងធម្មជាតិ**

- ប្រាសាទនានាទាក់ទងវប្បធម៌ និងសាសនា
- តំបន់ឆ្នេរសមុទ្រដ៏ស្រស់បំព្រង
- តំបន់អេកូទេសចរណ៍ធម្មជាតិ





# ស្ថិតិទេសចរក្នុងឆ្នាំ២០១៨

- ចំនួនភ្ញៀវទេសចរអន្តរជាតិក្នុងឆ្នាំ ២០១៨៖

  ៦,២ លាននាក់ ↑១២%

- បង្កើតការងារផ្ទាល់៖

  ៦២.០០០ ការងារ

- ចំណូលពីទេសចរបរទេស

  ៤,៣៧ ពាន់លាន ↑២០%

# ប្រទេសទាំង១០ដែលមានទេសចរច្រើន មកទស្សនាកម្ពុជាឆ្នាំ២០១៨



# ស្ថិតិទេសចរខែមករាដល់មេសាឆ្នាំ២០១៩

## ចំនួនភ្ញៀវទេសចរអន្តរជាតិខែមករាដល់ខែមេសា៖

| មករា មេសា ២០១៨ | មករា មេសា ២០១៩ | ភាពខុសគ្នា % |
|---|---|---|
| ២,១៧ លាននាក់ | ២,៤១ លាននាក់ | ⇧ ១១,០៧% |



# ប្រទេសទាំង១០ដែលមានទេសចរច្រើន មកទស្សនាកម្ពុជាពីខែមករាដល់ខែមេសាឆ្នាំ២០១៩




| | China (RPC) | Vietnam | Lao PDR | Thailand | Korea (ROK) | U.S.A | Japan | U.K | France | Malaysia |
|---|---|---|---|---|---|---|---|---|---|---|
| 2019 | 887,039 | 265,728 | 154,943 | 127,085 | 111,044 | 97,526 | 77,354 | 72,410 | 71,589 | 65,354 |
| 2018 | 647,352 | 262,475 | 145,082 | 110,508 | 144,914 | 97,690 | 73,146 | 63,741 | 69,403 | 58,415 |
| Share (%) | 36.7 | 11.0 | 6.4 | 5.3 | 4.6 | 4.0 | 3.2 | 3.0 | 3.0 | 2.7 |
| Change (%) | 37.0 | 1.2 | 6.8 | 15.0 | -23.4 | -0.2 | 5.8 | 13.6 | 3.1 | 11.9 |

# យន្តការសម្រាប់ការពារកុមារ

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ( គ.ជ.ប.ជ. )

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.)** មានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការដឹកនាំសម្របសម្រួល ទំនាក់ទំនង សហការរវាងក្រសួងស្ថាប័ននានា ជាមួយអង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន និងបណ្តាប្រទេសពាក់ព័ន្ធសំដៅបង្ការទប់ស្កាត់ និងឈានទៅលុបបំបាត់អំពើជួញដូរមនុស្ស ការពារជនរងគ្រោះ និងផ្តន្ទាទោសជនល្មើសជួញដូរមនុស្សតាមច្បាប់។
- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ដែលមានក្រសួង និងស្ថាប័នពាក់ព័ន្ធចំនួន ២៧។

# រចនាសម្ព័ន្ធគណៈកម្មាធិការជាតិប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស ( គ.ជ.ប.ជ. )



# ទេសចរណ៍ និងសុវត្ថិភាពកុមារ

- រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវគោលនយោបាយ **“ទេសចរណ៍វប្បធម៌ និងធម្មជាតិ”** ជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា ។
- គ្មានការលើកទឹកចិត្តចំពោះ **ទេសចរណ៍ផ្លូវភេទ** និងប្រឆាំងដាច់ខាត **ទេសចរណ៍ផ្លូវភេទលើកុមារ** ។
- ការរីកចម្រើននៃវិស័យទេសចរណ៍កម្ពុជាបានឆ្លុះបញ្ចាំងយ៉ាងប្រត្យក្សអំពីសារៈសំខាន់ នៃកត្តាសន្តិសុខ សុវត្ថិភាព ស្ថិរភាពនយោបាយ ដែលជាកត្តាកំណត់និងជាមូលដ្ឋានសម្រាប់ធានាចីរភាពកំណើននៃវិស័យទេសចរណ៍ ។

# គណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

- ទន្ទឹមនឹងការរីកចម្រើននៃវិស័យទេសចរណ៍ សកម្មភាពអវិជ្ជមានមួយចំនួន ត្រូវបានកើតឡើងដូចជាៈ ឧក្រិដ្ឋកម្ម ពេស្យាចារ ការជួញដូរមនុស្ស ការរំលោភផ្លូវភេទលើកុមារ ការជួញដូរគ្រឿងញៀន។ល។
- **គណៈកម្មាធិការសុវត្ថិភាពកុមាររបស់ក្រសួងទេសចរណ៍** បានធ្វើការយ៉ាងជិតស្និទ្ធជាមួយបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធ រួមជាមួយផ្នែកឯកជន និងអង្គការសង្គមស៊ីវិលដើម្បីលុបបំបាត់ទេសចរណ៍ផ្លូវភេទលើកុមារនិងការពារមិនឲ្យមានផលប៉ះពាល់អវិជ្ជមានដល់វិស័យទេសចរណ៍ ជាមួយបញ្ហា **រំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍**។

# គណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

- ជនល្មើសជាច្រើនត្រូវផ្តន្ទាទោស ក្នុងនោះរួមមានជនបរទេសដែលប្រព្រឹត្តអំពើអនាចារលើកុមារផងដែរ។
- ការរំលោភបំពានផ្លូវភេទលើកុមារអាចបង្កឡើងមនុស្សផ្សេងៗគ្នា មកពីប្រទេសខុសៗគ្នា និងជាអ្នកប្រកបមុខរបរមិនដូចគ្នា។
- មិនថាជាអ្នកជំនួញ ជាគ្រូបង្រៀន ជាអ្នកស្ម័គ្រចិត្ត ឬជាក៏ស្ថិតក្នុងអាជីពណាមួយឡើយ។

# គណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

វិធានការចំនួនពីរដែលគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍បាន និងកំពុងអនុវត្ត៖

- វិធានការអប់រំ
- វិធានការរដ្ឋបាល

# គណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

## វិធានការអប់រំ

អប់រំសាធារណជន ក៏ដូចជាផ្នែកដែលពាក់ព័ន្ធអំពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍។

- រៀបចំសិក្ខាសាលាអប់រំទៀងទាត់
- បោះពុម្ពសម្ភារៈផ្សព្វផ្សាយ (ស្ទីកគ័រ ផ្ទាំងបាណូ ។ល។)

# គណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

## វិធានការរដ្ឋបាល

ម្ចាស់សណ្ឋាគារ ឬអ្នកគ្រប់គ្រង និងបុគ្គលិកបានទទួលការបណ្តុះបណ្តាល និងផ្សព្វផ្សាយពីការចូលរួមសហការទប់ស្កាត់មិនឲ្យមានអំពើពេស្យាចារកុមារ/ទេសចរណ៍ផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ កើតមានក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួនឡើយ។

- ក្នុងករណីកើតមានឡើង មូលដ្ឋានអាជីវកម្ម សេវាកម្មទាំងនោះនឹងត្រូវប្រឈមជាមួយនឹងការព្យួរអាជ្ញាបណ្ណ ដកហូត ឬបញ្ឈប់អាជីវកម្មតែម្តង ហើយនឹងទទួលទោសតាមច្បាប់កំណត់។

# សន្និដ្ឋាន

- កម្ពុជាបានរៀបចំយន្តការរឹងមាំក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ការពង្រឹងអនុវត្តច្បាប់នៅកម្ពុជា និងយន្តការច្បាស់លាស់ ជួយការពារកុមារពីការរំលោភបំពានផ្លូវភេទពីជនបរទេស។
- យើងបានបង្កើតសារអប់រំយ៉ាងច្បាស់លាស់ ដែលបញ្ជាក់ថា ជនណាដែលរំលោភបំពានផ្លូវភេទលើកុមារទាំងអស់នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។
- កិច្ចខិតខំប្រឹងប្រែងក្នុងការលុបបំបាត់ការរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍សម្រេចបានលទ្ធផលគួរឲ្យកត់សម្គាល់។

# សន្និដ្ឋាន

- ការការពារ និងពង្រឹងសុវត្ថិភាពកុមារ បានចូលរួមចំណែកលើកស្ទួយវប្បធម៌ប្រពៃណី ការលើកកម្ពស់សីលធម៌នៅក្នុងសង្គមគ្រួសារខ្មែរ ការយល់ដឹងពីតម្លៃនិងសិទ្ធិរបស់កុមារ ព្រមទាំងកសាងមុខមាត់វិស័យទេសចរណ៍កម្ពុជាជាទេសចរណ៍វប្បធម៌ និងធម្មជាតិពិតៗ។
- ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអំពាវនាវដល់អ្នកធ្វើដំណើរទាំងអស់ សូមមេត្តាប្រកាន់យកនូវសីលធម៌វិជ្ជាជីវៈក្នុងការធ្វើដំណើរ ដោយកុំប្រព្រឹត្តនូវអ្វីៗដែលខុសនឹងច្បាប់នៃប្រទេសដែលបានទៅទស្សនា៕


សូមអរគុណ